# សង្ខេបទិន្នន័យថ្មីៗនៃកុលាលភាជន៍ខ្មែរ

អ៊ា ដារិទ្ធ

កាលណាគេសិក្សាទៅលើអារ្យធម៌អង្គរ គេច្រើនផ្តោតការស្រាវជ្រាវទៅលើសំណង់ស្ថាបត្យកម្មធំៗ ប្រាសាទ សិលាចារិក និងបារាយជាដើម។ គេពុំសូវបានយកចិត្តទុកដាក់លើសិប្បកម្ម ផ្ញើដែក សម្រិត និងកុលាលភាជន៍ទេ។ ទោះបីជាលោក Etienne Aymonier បានរកឃើញឡបុរាណនៅលើខ្នងភ្នំគូលែន តាំងពីឆ្នាំ១៨៨៣ ក៏ដោយ។ ទាល់តែដល់រវាងសម័យសង្គ្រាម ទើបលោក B.-Ph. Groslier, អ្នកស្រី R.M. Brown, អ្នកស្រី D.F. Roony និងលោក J. Guy ជាដើមដែលជាអ្នកស្រាវជ្រាវ បានចាប់ផ្តើមសិក្សាទៅលើកុលាលភាជន៍ខ្មែរ។

ប៉ុន្មានឆ្នាំកន្លងទៅនេះ នៅតំបន់អង្គរ គេរកឃើញស្ថានីយ៍ឡបុរាណចំនួន ៥កន្លែងជាបន្តបន្ទាប់ ដែលមានដុតកុលាលភាជន៍មានស្រទាប់រលោងពណ៌បៃតង (green glaze), គ្មានស្រទាប់រលោង (unglazed) និងក្បឿង។

## ១_ ឡនៅស្រុកខ្មែរដែលអ្នកស្រាវជ្រាវទើបនឹងចាប់អារម្មណ៍

ស្ថានីយ៍ឡបុរាណ នៅតំបន់អង្គរប្រហែលមានច្រើន ក៏ប៉ុន្តែរហូតមកទល់នឹងពេលនេះ គេប្រទះឃើញចំនួនតែ ៥ប៉ុណ្ណោះ។

### ១_១_ ឡអន្លង់ធំ *(រូបថតទី១_២)*

ស្ថិតនៅក្នុងភូមិអន្លង់ធំ ឃុំខ្នងភ្នំ ស្រុកស្វាយលើ ចំងាយប្រហែល ៦គ.ម.ខាងពាយព្យព្រះអង្គធំ និងប្រហែល ៤០គ.ម.ខាងឦសានអង្គរវត្ត។ ឡនេះលាតសន្ធឹងពីជើងទៅត្បូង ប្រវែងប្រហែល ១០០០ម៉ែត្រ ពីលិចទៅកើតប្រហែល ៥០០ម៉ែត្រ។ ឡទាំងនេះស្ថិតនៅជិតៗគ្នា រាងមូលនិងមូលទ្រវែង។ កុលាលភាជន៍នៅមានសល់ល្អៗច្រើន មានស្រទាប់រលោងពណ៌បៃតង គុណភាពល្អ និងកម្រាសស្រទាប់រលោងក្រាស។ បច្ចេកទេសធ្វើមានការផ្ចិតផ្ចង់ ទំហំធំបន្តិច និងមានក្បាច់លំអច្រើនប្រភេទ។

វត្ថុមកពីស្ថានីយ៍នេះ មាន៣ប្រភេទធំៗគឺ ភាជន៍មានស្រទាប់រលោងពណ៌បៃតង, គ្មានស្រទាប់រលោង និងក្បឿង។ ភាជន៍ដែលមានស្រទាប់រលោងពណ៌បៃតង ភាគច្រើន ទំហំតូចៗ មានចំនួនច្រើនជាងប្រភេទផ្សេងទៀត។ រាងរៅវា មានកោដ្ឋ តន្លាប់ ខ្ទប និងចានគោម។ ភាជន៍គ្មានស្រទាប់រលោង មានទំហំធំជាងនោះ ប៉ុន្តែមានចំនួនតិចបំផុត។ យើងប្រទះឃើញតែក្អមប៉ុណ្ណោះ។ រីឯក្បឿងវិញ ភាគច្រើនមានស្រទាប់រលោងពណ៌បៃតងចំនួន ៤ប្រភេទគឺ ក្បឿងផ្កាប់ ផ្ងារ រងស្បូវ និងក្បឿងលំអព្រំដំបូល។

ក្រៅពីនោះ គេក៏ប្រទះឃើញកំណល់ទ្រភាជន៍កុំឲ្យដួលនៅពេលដុតដែរ។ កំណល់ទ្រនោះ មានរាងមូលទ្រវែងរាងដូចអក្សរ "I"។




រូបថតទី១. បំណែកគម្របកោដ្ឋ មានស្រទាប់រលោងពណ៌បៃតង (ឡអន្លង់ធំ)



រូបថតទី២
បំណែកខួច កោដ្ឋនិងក្បឿង
មានស្រទាប់រលោងពណ៌បៃតង,
បំណែកក្អម គ្មានស្រទាប់រលោង
និងកំណល់ទ្រភាជន៍
(ឡអន្លង់ធំ)

១_២_ ឡសរសី (រូបថតទី៣_៦)

ស្ថិតនៅក្នុងភូមិសរសី ឃុំត្បែង ស្រុកបន្ទាយស្រី ចំងាយប្រហែល ២៥គ.ម.ពីប្រាសាទអង្គរវត្តទៅទិសឦសាន។ ឡនេះចែកជា២ក្រុម"ក" និង"ខ"។ ក្រុម"ក" ស្ថិតលើខ្នងទំនប់ខាងលិចនៃត្រពាំងស្នាយ និងឡមួយទៀតក្រុម"ខ" ស្ថិតនៅចំងាយប្រហែល ៥០០ម៉ែត្រ ខាងត្បូងឡត្រពាំងស្នាយ, ក្បែរស្ទឹងតូចមួយ។ ឡក្រុម"ក" មានដុតភាជន៍គ្មានស្រទាប់រលោងច្រើន ឯឡក្រុម"ខ" ដុតភាជន៍មានស្រទាប់រលោងច្រើន ជាពិសេសពពួកខួច មានទំហំធំជាងនៅឡដ៏ទៃ។ នៅគែមនៃមាត់របស់វា មានលំអដោយក្បាច់ពកត្រួតៗលើគ្នាច្រើនជាន់។

កុលាលភាជន៍ចេញពីឡទាំងនេះ ភាគច្រើននៅសេសសល់បំណែកល្អៗច្រើន ខ្លះស្ទើរនៅសល់ទាំងមូល។ គេចែកចេញជា៣ប្រភេទគឺ ភាជន៍មានស្រទាប់រលោងពណ៌បៃតង ដូចជាកោដ្ឋ តន្លាប់ ខួច និងចានគោម។ ភាជន៍គ្មានស្រទាប់រលោង មានពាង ក្អម និងក្រឡត្រចៀកបួន។ ក្បឿងមាន៤ប្រភេទគឺ ក្បឿងផ្ទារ ផ្កាប់ រងស្បូវ និងក្បឿងលំអព្រំដំបូល។



រូបថតទី៣. បំណែកគម្របកោដ្ឋ មានស្រទាប់រលោងពណ៌បៃតង (ឡសរសី)



រូបថតទី៤. បំណែកខួច មានស្រទាប់រលោងពណ៌បៃតង (ឡសរសី)



រូបថតទី៥
បំណែកចានគោម
មានស្រទាប់រលោង
ពណ៌បៃតង
(ឡសរសី)



រូបថតទី៦. បំណែកក្អម និងពាង
គ្មានស្រទាប់រលោង (ឡសរសី)

១_៣_ ឡតានី (រូបថតទី៧_១១)

ស្ថិតនៅភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី ចំងាយប្រហែល ២០គ.ម. ឦសាននៃអង្គរវត្ត ក្បែរភ្នំបូក។ ឡទាំងនេះ មានចំនួន២៥ ហើយចែកចេញជា៥ក្រុម។ ក្រុម"ក" មានឡ៦, ក្រុម"ខ" មានឡ៧, ក្រុម"គ" មានឡ៣, ក្រុម"ឃ" មានឡ១ និងក្រុម"ង" មានឡ៩។ រូបរាងឡ មាន២ប្រភេទ ទំហំខុសៗគ្នាគឺ រាងមូល និងមូលទ្រវែង។

កុលាលភាជន៍មកពីឡនេះ ភាគច្រើននៅសល់បំណែកតូចៗ មាន៣ប្រភេទគឺ ភាជន៍មានស្រទាប់រលោង, គ្មានស្រទាប់រលោង និង ក្បឿង។ ភាជន៍មានស្រទាប់រលោងពណ៌បៃតង ភាគច្រើនមានគុណភាពមិនសូវល្អទេ ស្រទាប់រលោងពណ៌រាងលឿងភ្លាវ មិនសូវស្អិតជាប់និងខ្លួនភាជន៍។ ការធ្វើមិនសូវផ្ចិតផ្ចង់ មានទំហំតូចជាងវត្ថុមកពីឡអន្លង់ធំ និងសរសី។ រាងរៅវា មានកោដ្ឋ តន្លាប់ ខ្ទច ក្រឡមូល និងចានគោម ។ល។ ឯភាជន៍គ្មានស្រទាប់រលោងវិញមានចំនួនច្រើន ប៉ុន្តែមានតែ៣ប្រភេទទេ គឺក្អម ពាង និងក្រឡត្រចៀកបួន។ ចំពោះក្បឿង ក៏មាន៤ប្រភេទដែរ ភាគច្រើនគ្មានស្រទាប់រលោងទេ។ ក្បឿងទាំងនោះ មានក្បឿងផ្កាវ ផ្កាប់ វងស្បូវ និងក្បឿងលំអព្រំដំបូល។



រូបថតទី៧. បំណែកគម្របកោដ្ឋ តន្លាប់ និងខ្ទច មានស្រទាប់រលោងពណ៌បៃតង (ឡតានី)



រូបថតទី៨
បំណែកក្អម គ្មាន
ស្រទាប់រលោង
(ឡតានី)




រូបថតទី៩. បំណែកក្រឡត្រចៀកបួន គ្មានស្រទាប់រលោង (ឡតានី)



រូបថតទី១០. បំណែកជើង គ្មានស្រទាប់រលោង (ឡតានី)




រូបថតទី១១. បំណែកក្បឿង គ្មានស្រទាប់រលោង (ឡតានី)

១_៤_ ឡបាកោង (រូបថតទី១២_១៣)

ស្ថិតនៅក្នុងភូមិបាកោង ស្រុកប្រាសាទបាគង មានចំងាយប្រហែល ១៣គ.ម. ខាងកើតនៃប្រាសាទអង្គរវត្ត។ គេមិនដឹងចំនួនឡពិតប្រាកដទេ ព្រោះត្រូវគេឈូសចាយធ្វើផ្លូវ ធ្វើឲ្យខូចខាតអស់ឡបុរាណមួយចំនួន។ រីឯឡខ្លះដែលនៅក្នុងដីឯកជន ក៏ត្រូវគេគាស់ធ្វើចំការដាំដំណាំខូចអស់។

ឡនេះមានចំនួនតិច កុលាលភាជន៍ភាគច្រើនគ្មានស្រទាប់រលោង ទំហំធំៗ មានដូចជាក្អម និងពាងតែប៉ុណ្ណោះ។ យើងសង្ស័យថាប្រហែលជាមានដុតភាជន៍ស្រទាប់រលោងតូចៗដែរ ព្រោះយើងរកឃើញកំណល់សម្រាប់ទ្រភាជន៍តូចៗ ដែលមានរាងដូចក្រចកសេះ។ ឯក្បឿងវិញ យើងពុំបានប្រទះបំណែកវាទេ។



រូបថតទី១២. បំណែកក្អម និងជើង គ្មានស្រទាប់រលោង (ឡបាកោង)



រូបថតទី១៣. បំណែកកំណល់ទ្រកុលាលភាជន៍ប្រភេទតូច (ឡបាកោង)

១_៥_ ឡខ្នារពោធិ៍ (រូបថតទី១៤)

ស្ថិតនៅក្នុងភូមិបុស្ស ឃុំខ្នារពោធិ៍ ស្រុកសូទ្រនិគម ចំងាយប្រហែល ២០គ.ម. ខាងកើតទីរួមខេត្តសៀមរាប។ ឡនេះស្ថិតនៅលើខ្នងខាងលិចនៃបារាយតូចមួយ ដែលអ្នកស្រុកនិយមហៅថា "ទន្លេបិទ "។ ឡទាំងអស់មានចំនួន១៣ លាតសន្ធឹងពីជើងទៅត្បូង។ ខាងលើខ្នងទំនប់ មានឡ១០ តំរៀបគ្នា ពីជ្រុងខាងត្បូងឈៀងខាងលិចនៃទន្លេបិទ ទៅដល់វត្តព្រះអង្គបួនថាន។ ឯឡ៣ទៀតស្ថិតនៅខាងលិចនៃខ្នងទំនប់ខាងលិចប្រហែល ៥០ម៉ែត្រ។

កុលាលភាជន៍ ភាគច្រើនស្ទើរតែគ្មានស្រទាប់រលោង ជារបស់ធំៗដូចជាពាង ក្អម និងក្រឡត្រចៀកបួន។ ឯក្បឿងមាន៤ប្រភេទគឺ ក្បឿងផ្ការ ផ្កាប់ រងស្បូវ និងក្បឿងលំអព្រំដំបូល។



រូបថតទី១៤. បំណែកក្បឿងនិងក្អម គ្មានស្រទាប់រលោង (ឡខ្នារពោធិ៍)

## ២_ ប្រភេទកុលាលភាជន៍ដែលរកឃើញ

តាមរយៈវត្ថុដែលរកឃើញពីឡទាំង៥នៅតំបន់អង្គរ យើងអាចបែងចែកជា៣ប្រភេទធំៗ គឺភាជន៍មានស្រទាប់រលោងពណ៌បៃតង, គ្មានស្រទាប់រលោង និងក្បឿង។

### ២_១_ កុលាលភាជន៍មានស្រទាប់រលោងពណ៌បៃតង (គំនូរទី១)

កុលាលភាជន៍មានស្រទាប់រលោងពណ៌បៃតង ភាគច្រើនជាភាជន៍ប្រភេទតូចៗ ដូចជាកោដ្ឋ តន្លាប់ ខ្ចូច ក្រឡមូលតូច និងចានគោម។ ជួនកាល គេក៏ឃើញមានស្រទាប់រលោងពណ៌បៃតងនៅលើភាជន៍ប្រភេទធំដែរ ដូចជាក្អមនៅឡអន្លង់ធំជាដើម។

#### ២_១_១_ កោដ្ឋ

មានច្រើននៅឡអន្លង់ធំ និងឡសរសី ហើយមានគុណភាពល្អ។ ឡតានីមានតិចតួច ឯគុណភាពក៏មិនសូវល្អប៉ុន្មានទេ។ ជាទូទៅ ដងខ្លួនវារាងស៊ីឡាំងផ្គុំជាមួយគម្របមូលកន្លះរង្វង់ ឬមូលសំប៉ែត។ មានស្រទាប់រលោងជុំវិញខ្លួន និងគម្រប លើកលែងតែកន្លែងទទួលគម្រប។ ទំហំធំ និងតូច កំពស់ពី ១១,៥ទៅ១៦,៥ស.ម. អង្កត់ផ្ចិតគម្របពី ១១ទៅ១៧ស.ម.។ នៅផ្នែកខាងលើនៃគម្រប និងផ្នែកខាងក្នុងនៃកោដ្ឋ មានស្នាមជុំជីឥដ្ឋរាងមូលតូចៗ អង្កត់ផ្ចិតពី ២ទៅ៣ស.ម. ចំនួន ៣ឬ៤កន្លែង។ របៀបនេះ ភាគច្រើនយើងឃើញនៅលើភាជន៍មកពីឡអន្លង់ធំ។ គម្របមាន២ប្រភេទគឺ រាងមូលសំប៉ែតគ្មានប្រដាប់ចាប់កាន់ និងមួយប្រភេទទៀតរាងកន្លះរង្វង់ មានប្រដាប់ចាប់កាន់ដែលមានរាងដូចជាសាជី។ នៅជុំវិញកំពោយចាប់កាន់ គេឃើញមានក្បាច់លំអផ្សេងៗ ដូចជារាងផ្កាយ ផ្កាឈូក ធ្មេញរណារ និងខ្សែបន្ទាត់ជាដើម។

#### ២_១_២_ តន្លាប់

មានច្រើននៅឡសរសី និងតានី។ ដងខ្លួន និងគម្រប មានរាងជាកន្លះរង្វង់ ដាក់គ្របពីលើគ្នា។ មានពីរប្រភេទទំហំធំ និងតូច កំពស់ពី ៤ទៅ៧ស.ម. អង្កត់ផ្ចិតពី ៥,២ទៅ៨ស.ម.។ នៅជុំវិញតួខ្លួន និងគម្រប មានស្រទាប់រលោងពណ៌បៃតង លើកលែងតែកន្លែងទទួលគម្រប។ នៅបាតរបស់វា ភាគច្រើនមានស្នាមគូស ២ឬ៣ជួត។

#### ២_១_៣_ ខ្ចូច

មានច្រើននៅឡអន្លង់ធំ សរសី និងតានី។ ខ្ចូចនៅឡសរសីមានលក្ខណៈពិសេសខុសគេ មានទំហំធំ គែមមាត់មានលំអដោយក្បាច់ពកត្រួតលើគ្នាច្រើនជាន់។ មានទំហំធំ និងតូច ប៉ុន្តែរាងដូចគ្នា កំពស់ពី ៧,៥ទៅ១៣ស.ម.។ កវារាងតូច មាត់រីកបើកចេញមកក្រៅ ហើយនៅផ្នែកគែមនៃមាត់របស់វា មានលំអដោយក្បាច់ពកចំនួន ៣ឬ៤ភ្នក។ ដងខ្លួនរាងមូលដូចបាល់ នៅលើក្អែងក៏មានលំអដោយក្បាច់ពកចំនួន ៣ឬ៤ភ្នកដែរ។ នៅជុំវិញពោះរបស់វា មានលំអដោយក្បាច់រាងជាផ្កាយ ផ្កាឈូក ឬធ្មេញរណារ ដូចគំរបកោដ្ឋដែរ។ ជុំវិញខ្លួនមានលាបស្រទាប់រលោងពណ៌បៃតង។




**គំនូរទី១. កុលាលភាជន៍មានស្រទាប់លោងពណ៌បៃតង**

១_១១. គម្របតន្ទាប់និងកោដ្ឋ

១២_១៩. ដងខ្លួនតន្ទាប់និងកោដ្ឋ

២០_២១. ខ្លូច

២២. ក្រឡមូលតូច

២_១_៤_ កូនក្រឡមូល

ជាប្រភេទភាជន៍កម្របំផុត យើងរកឃើញបន្តិចបន្តួចប៉ុណ្ណោះនៅឡតានី។ យើងដឹងទំហំភាជន៍ប្រភេទតូចច្បាស់ ដោយយើងរកឃើញបំណែកមួយនៅសេសសល់ពីមាត់ដល់បាត។ វាមានកំពស់តែ ៣,១ស.ម. អង្កត់ផ្ចិតមាត់តែ ៤ស.ម.ប៉ុណ្ណោះ។ មាត់វាខ្លី ដងខ្លួនមូលដូចបាល់ គ្មានលំអអ្វីឡើយ។ នៅជុំវិញខ្លួន មានលាបស្រទាប់រលោងពណ៌បៃតង។

២_១_៥_ ចានគោម

មាននៅឡអន្លង់ធំ សរសី និងតានី។ ទំហំធំ និងតូច អង្កត់ផ្ចិតមាត់ពី ៩ទៅ១៥ស.ម.។ រូបរាងដូចជាសាជី ដែលគេកាត់ផ្នែកកំពូលស្រួចចេញ ហើយផ្ងារឡើងលើ។ និយាយឲ្យស្រួលយល់គឺ មាត់រីកធំ ហើយរួមបន្តិចម្តងៗមកផ្នែកបាតវិញ។ ផ្នែកគែមនៃមាត់របស់វា មានលំអដោយក្បាច់ពកចំនួន ៣ឬ៤ភ្នក។ នៅផ្នែកខាងក្នុង និងខាងក្រៅ មានបន្ទប់ទូរជុំជីវជួចំនួន ៣ឬ៤កន្លែង ដែលមានទំហំពី ២ទៅ៣ស.ម.។ ជុំវិញខ្លួនវា ៣សទៅដោយស្រទាប់រលោងពណ៌បៃតង។

២_២_ កុលាលភាជន៍គ្មានស្រទាប់រលោង (គំនូរទី២)

កុលាលភាជន៍គ្មានស្រទាប់រលោង ច្រើនជារបស់ធំៗ ដូចជាក្អម ៣ង និងក្រឡត្រចៀកបួន។ ភាជន៍ប្រភេទទាំងនេះ មានផលិតស្ទើរតែនៅគ្រប់ឡទាំងអស់។

២_២_១_ ក្អម

មាននៅគ្រប់ឡទាំងអស់ ភាគច្រើនគ្មានស្រទាប់រលោងទេ ប៉ុន្តែនៅឡអន្លង់ធំ មានស្រទាប់រលោងពណ៌បៃតងដែរ។ ជាទូទៅ ជាប្រភេទភាជន៍ធំ មាត់រីកដូចឧបករណ៍ភ្លេងត្រុំប៉ែត ខ្លួនដូចជាគ្រាប់ក្បាច់គិតលេខចិន។ ទំហំធំ និងតូច ប៉ុន្តែរាងដូចគ្នា។ អង្កត់ផ្ចិតមាត់ពី ៨ទៅ១៥ស.ម. កំពស់ប្រហែលពី ៣០ទៅ៤០ស.ម.។ ផ្នែកគែមនៃមាត់ មានលំអដោយក្បាច់ពកចំនួន ៣ឬ៤ភ្នក។ នៅលើក្អេងវា ក៏មានលំអដោយក្បាច់ពកដែរចំនួន៧ឬ៨ភ្នក ហើយនៅចន្លោះនេះ ជួនកាល មានថែមក្បាច់លំអដោយយកឈើមកចុចពីលើជាចំណុចតូចៗ។ នៅលើពោះវា មានស្នាមខ្សែឆ្នូតចំនួន ២ឆ្នូត។

២_២_២_ ៣ង

មានស្ទើរតែនៅគ្រប់ឡទាំងអស់។ រាងដូចជាពាងធ្វើអំពីស៊ីម៉ង់ដែលគេប្រើសព្វថ្ងៃដែរ ប៉ុន្តែមានទំហំតូចជាងឆ្ងាយណាស់។ ផ្នែកគែមនៃមាត់របស់វា មានលំអដោយក្បាច់ពកចំនួន ៣ឬ៤ភ្នក។ នៅលើក្អេង ក៏មានលំអដោយក្បាច់ពកចំនួន ២ឬ៣ភ្នកដែរ។ អង្កត់ផ្ចិតមាត់ពី ៣២ទៅ ៤៧ស.ម.។ ជួនកាលមានចោះប្រហោងនៅបាតរបស់វាដែរ។

២_២_៣_ ក្រឡត្រចៀកបួន

មានស្ទើរតែនៅគ្រប់ឡទាំងអស់។ ប៉ុន្តែមានចំនួនតិចបំផុត បើប្រៀបធៀបទៅនិងភាជន៍ផ្សេងៗទៀត។ យើងរកឃើញភាគច្រើនត្រឹមតែពីក្អេងទៅមាត់ប៉ុណ្ណោះ ដូច្នេះយើងពុំដឹងរាងរៅផ្នែកខាងក្រោមរបស់វាច្បាស់ទេ។ នៅលើក្អេងមានលំអដោយត្រចៀកបួន គ្មានចោះប្រហោងសំរាប់ដោតខ្សែបញ្ចូលឡើយ។ អង្កត់ផ្ចិតមាត់ពី ១១ទៅ១៦ស.ម.។

២_៣_ ក្បឿង (គំនូរទី ៣)

ក្បឿងជាទូទៅ មាន៤ប្រភេទគឺ ក្បឿងផ្ងារ ផ្កាប់ រងស្បូវ និងក្បឿងលំអព្រំដំបូល។ ភាគច្រើនគ្មានលាបស្រទាប់រលោងទេ លើកលែងតែក្បឿងនៅឡអន្លង់ធំ មានស្រទាប់រលោងពណ៌បៃតង ហើយមានទំហំហាក់ដូចជាតូចជាងក្បឿងនៅឡផ្សេងៗ។

## ៣_ បច្ចេកទេស

តាមការធ្វើកំណាយខ្លះៗ ដែលចាប់ផ្ដើមធ្វើដោយស្ថាប័នអន្តរជាតិមួយចំនួន យើងអាចដឹងថា ទ្រង់ទ្រាយខាងក្នុងនៃឡនៅស្រុកខ្មែរ និងឡខ្មែរនៅស្រុកសៀម មានលក្ខណៈខុសគ្នាទាំងស្រុង។ គេចាត់ទុកឡខ្មែរនៅស្រុកសៀមជា "ឡខេត្ត" ព្រោះនៅឆ្ងាយពីរាជធានីអង្គរ។ ដូច្នេះទាំងរចនាសម្ព័ន្ធឡ ទាំងប្រភេទកុលាលភាជន៍ដែលផលិត គឺមានលក្ខណៈខុសៗគ្នា មិនដូចគ្នាទាំងអស់នោះទេ។

### ៣_១_ រចនាសម្ព័ន្ធឡ និងរបៀបផលិត

ឡតានី មានរាងមូលដូចពងក្រពើ ប្រវែងបណ្ដោយប្រហែល ៥ទៅ៦ម៉ែត្រ និងទទឹងឡផ្នែកធំបង្អស់ ២,៧ម៉ែត្រ។ ឡនេះចែកចេញជា៣ផ្នែកគឺ បន្ទប់ដុតភ្លើង បន្ទប់ដាក់ភាជន៍ដុត និងកន្លែងបង្ហុយផ្សែង។ នៅក្នុងឡ មានសសររាងមូល ដែលគេសន្និដ្ឋានថាជាសសរទ្រដំបូល ឬសសរសម្រាប់បែងចែកភ្លើង ដែលមានអង្កត់ផ្ចិតប្រហែល ៣០ស.ម.។ ឯឡខ្មែរខ្លះៗនៅខេត្តបុរីរាម ស្រុកសៀមវិញ មានតំរៀបគ្នាពី ៣ទៅ៥ នៅលើទួលតែមួយ ដោយប្រើជញ្ជាំងរួមគ្នា។ ប្រវែងប្រហែលពី ១២ទៅ១៥ម៉ែត្រ ទទឹងឡពី ០,៥ទៅ១,៥ម៉ែត្រ។ នៅកណ្ដាលឡមានសសររាងមូល អង្កត់ផ្ចិតប្រហែល ៣០ស.ម. ដែលគេចាត់ទុកថាជាសសរទ្រដំបូល ឬបែងចែកភ្លើង។ ឡទាំងនោះក៏ចែកជា៣ផ្នែកដែរគឺ បន្ទប់ដុតភ្លើង បន្ទប់ដាក់ភាជន៍ដុត និងកន្លែងបង្ហុយផ្សែង។

ខ្មែរប្រើវិធី២យ៉ាងក្នុងការធ្វើភាជន៍ គឺទី១ ប្រើកង់បង្វិល រួចបៀកពីខាងក្នុងដើម្បីចាប់រាងភាជន៍។ វិធីនេះឃើញច្រើនប្រើចំពោះភាជន៍តូចដូចជា កោដ្ឋ តន្លាប់ និងចានគោម ។ល។ ឯវិធីម្យ៉ាងទៀតគឺ គេយករមូរដីឥដ្ឋមកបន្តុបលើគ្នា រួចរំលីងជាក្រោយ។ វិធីនេះ គេអនុវត្តន៍ទៅលើភាជន៍ដែលមានទំហំធំ ដូចជាពាង ក្អម និងក្រឡត្រចៀកបួន។

ពេលគេសូនវារួច គេត្រូវការដុតវា។ ប៉ុន្តែដើម្បីចំណេញកន្លែង គេត្រូវតែគិតពីការតំរៀបគ្នាយ៉ាងណាដើម្បីឲ្យដុតបានច្រើន និងមានគុណភាពល្អ។ ក្នុងនោះយើងសង្កេតឃើញថា គេយករបស់តូចៗ ដូចជាតន្លាប់ ទៅដាក់ក្នុងកោដ្ឋ ឬកោដ្ឋដាក់ត្រួតលើកោដ្ឋគ្នាវា និងគំរបកោដ្ឋក៏ដាក់ត្រួតគ្នាដែរ។ ប៉ុន្តែ គេប្រើដុំដីឥដ្ឋមូលតូចៗសំរាប់កល់ចន្លោះភាជន៍ទាំងពីរកុំឲ្យស្អិតជាប់គ្នានៅពេលដុត។ ភស្តុតាងទាំងនេះ យើងមានគ្រប់គ្រាន់សំរាប់អះអាង។ រីឯរបស់ធំៗវិញ ដូចជាមានភាពស្មុគស្មាញបន្តិច ក្នុងការតំរៀបគ្នាដើម្បីដុត។ យើងឃើញភាជន៍៣ប្រភេទខុសៗគ្នា ដាក់ត្រួតលើគ្នា ខាងក្រោមគឺក្រឡត្រចៀកបួន កណ្ដាលគឺពាង និងខាងលើគឺក្អម។ បើនិយាយឲ្យស្រួលយល់គឺ ខាងក្រោម គេដាក់ក្រឡត្រចៀកបួនបញ្ឈរ រួចដាក់ពាងផ្កាប់ពីលើ និងចុងក្រោយ ដាក់ក្អមផ្កាប់ពីលើគូថពាងទៀត។ របៀបនេះយើងក៏មានភស្តុតាងច្បាស់លាស់ដែរ។ វិធីដ៏សាមញ្ញមួយទៀតគឺ គេដាក់ជើងត្រួតៗគ្នាដុតតែម្ដង។ ក្រោយពីពេលដុតរួច នៅក្នុងឡតែមួយ គេឃើញភាជន៍ទាំងនោះ មានពណ៌ខុសៗគ្នា ព្រមទាំងគុណភាពក៏ខុសៗគ្នាដែរ។ នេះប្រហែលមកពីការទទួលកំដៅ មិនស្មើគ្នានៅក្នុងឡ។ ដូច្នេះ យើងអាចបែងចែកគុណភាព និងពណ៌នៃកុលាលភាជន៍ទាំងនោះជា៤ប្រភេទគឺ៖

ប្រភេទ ក: គុណភាពទន់ផុយជាងគេ ដុតឡើងពណ៌រាងលឿងខ្ចី មានចំនួនតិចបំផុត។

ប្រភេទ ខ: រឹងជាងប្រភេទ "ក" ដុតឡើងពណ៌រាងប្រផេះស្រអាប់ ចំនួនមិនសូវច្រើនដែរ។

ប្រភេទ គ: ក៏រិតរឹងខ្លាំង ដុតឡើងពណ៌ក្រហមក្រម៉ៅ មានចំនួនច្រើន។

ប្រភេទ ឃ: ក៏រិតរឹងខ្លាំងដែរ មើលមួយភ្លែតហាក់ដូចជាមានស្រទាប់រលោងពណ៌ត្នោត។ នេះដោយសារកំដៅ និងអណ្ដាតភ្លើងជះចំខ្លាំង ធ្វើឲ្យវាក្លាយជាពណ៌បែបនេះ។

### ៣_២_ ដីឥដ្ឋ

យើងសង្កេតឃើញថា ដោយយោងទៅតាមភាជន៍តូចឬធំ គេប្រើដីឥដ្ឋ២ប្រភេទខុសៗគ្នាគឺ ស និងក្រហម។ ដីឥដ្ឋពណ៌ស ភាគច្រើនសំរាប់ធ្វើភាជន៍ដែលមានទំហំតូចៗ និងមានស្រទាប់រលោងពណ៌បៃតងផងដូចជា កោដ្ឋ ខ្ចូច តន្លាប់ ក្រឡមូលតូច និងចានគោម ។ល។ ដីឥដ្ឋនេះមានលាយគ្រាប់ខ្សាច់តូចៗ ហើយហាប់ណែនល្អទៀតផង។ ឯដីឥដ្ឋពណ៌ក្រហមវិញ ភាគច្រើនសំរាប់ធ្វើភាជន៍ធំៗដូចជា ពាង ក្អម និងក្រឡត្រចៀកបួន។ ដីឥដ្ឋប្រភេទនេះ គ្រើម មានលាយដុំគ្រួសធំៗបន្តិច មិនសូវហាប់ណែនល្អ មានជាតិដែកច្រើន ពេលដុតទៅរលាយជាប់ល្អិតលើភាជន៍។

៣_៣_ ស្រទាប់រលោង

ខ្មែរប្រើស្រទាប់រលោងដែលមានពណ៌តិចបំផុតគឺ ពណ៌បៃតង និងត្នោត។ ភាជន៍ដែលរកឃើញនៅឡទាំង៥នៅអង្គរ មានស្រទាប់រលោងពណ៌បៃតង ហើយមានគុណភាពខុសៗគ្នាទៅតាមឡនីមួយៗ។ ភាជន៍នៅឡអន្លង់ធំ និងសរសី ស្រទាប់រលោងពណ៌បៃតង មានគុណភាពល្អ ជាតិស្រទាប់រលោងនៅស្អិតជាប់និងភាជន៍ល្អ កម្រាសក្រាស និងមានកកក្រាមរបៀបដូចកញ្ចក់ប្រេះ។ ឡទាំងនេះ មិនត្រឹមតែស្រទាប់រលោងមានគុណភាពល្អទេ រាងរៅធំបន្តិច បច្ចេកទេសធ្វើផ្ចិតផ្ចង់ ក្បាច់លំអក៏មានច្រើនប្រភេទ ។ល។ រីឯភាជន៍ដែលមានស្រទាប់រលោងមកពីឡតានីវិញ មានគុណភាពអន់ជាង។ ស្រទាប់រលោង មិនសូវស្អិតជាប់និងភាជន៍ ឯកម្រាសក៏ស្តើង។ រូបរាង មិនសូវស្អាត ទំហំតូចបន្តិច។

សារុបមកកាលពីមុន គេបានសិក្សាកុលាលភាជន៍ខ្មែរខ្លះៗដែរ អំពីឡខ្មែរដែលនៅស្រុកសៀម។ ប៉ុន្តែឥឡូវនេះ គេបានរកឃើញឡខ្លះៗ នៅតំបន់អង្គរក្បែររាជធានីចាស់។ យើងក៏បានចាប់ផ្តើមស្រាវជ្រាវ ហើយប្រមូលបានទិន្នន័យថ្មីខ្លះៗ អំពីកុលាលភាជន៍ខ្មែរ សម្រាប់ធ្វើការស្រាវជ្រាវទៅថ្ងៃមុខទៀត និងដើម្បីឆ្ពោះទៅរកការចងក្រងកាលប្បវត្តិនៃកុលាលភាជន៍ខ្មែរទាំងមូល។




ផែនទីស្ថានីយ៍ឡបុរាណទាំង៥នៅតំបន់អង្គរ




*Villages in Mainland Southeast Asia following the "Khmer" pattern of earthenware production (Map by Daniel Cole, Geographic Information Systems Coordinator, Smithsonian Institution).*

*Key:*

*Cambodia*

*CA-01: Phnom Chisor*
*CA-02: Damdek*
*CA-03: Banh Chkoul*
*CA-04: Andong Russei*
*CA-05: Santuk*

*Vietnam*

*VT-05: An Loc*
*VT-06: Đầu Doi*

*Thailand*

*Dots indicate settlements of Thai-Khorat potters.*